# សុន្ទរកថា

# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុង
## ពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និង កីឡា
## ឆ្នាំសិក្សា ២០២០-២០២១ និង ទិសដៅសម្រាប់ឆ្នាំសិក្សា ២០២១-២០២២

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០២២

- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ;
- អង្គសន្និបាតទាំងមូល, ជាទីមេត្រី !

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សជាអនេក ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ **សម្តេចអគ្គមហាសេនបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតីក្នុង **ពិធីបើកសន្និបាតបូកសរុបការងារអប់រំ យុវជន និង កីឡា ឆ្នាំសិក្សា ២០២០-២០២១ និង ទិសដៅឆ្នាំសិក្សា ២០២១-២០២២** ។

ជាមួយគ្នានេះ, ខ្ញុំក៏មានសេចក្តីរីករាយ ដោយបានមកជួបដោយផ្ទាល់ជាមួយឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, លោកគ្រូ, អ្នកគ្រូ, សិស្សានុសិស្ស, និស្សិតទាំងអស់ ដែលការណ៍នេះបានឆ្លុះបញ្ចាំងឱ្យឃើញពីសមត្ថភាពឆ្លើយតប, កិច្ចខិតខំប្រឹងប្រែង និង ភាពបុរេសកម្មរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ, ចក្ខុវិស័យវែងឆ្ងាយ និង ការយកចិត្តទុកដាក់ខ្ពស់ ចំពោះសុខុមាលភាព និង អាយុជីវិតរបស់ប្រជាជន ពីសំណាក់ **សម្តេចអគ្គ-មហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការគ្រប់គ្រង

ស្ថានការណ៍នៃជំងឺកូវីដ-១៩ និង ផលប៉ះពាល់នៃវិបត្តិនេះមកលើសង្គម-សេដ្ឋកិច្ច បានយ៉ាងល្អប្រសើរ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ បើធៀបនឹងបណ្ដាប្រទេសនៅក្នុងតំបន់ ក៏ដូចជានៅលើសកលលោកទាំងមូល ។ ការអនុវត្តដោយជោគជ័យនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បានធ្វើឱ្យកម្ពុជាមានលទ្ធភាពបើកប្រទេស និង សង្គម-សេដ្ឋកិច្ចឡើងវិញពេញលេញ និង ធ្វើឱ្យប្រជាជនកម្ពុជាអាចប្រកបមុខរបរ និង អាជីវកម្មផ្សេងៗបានជាធម្មតា ហើយក្មួយៗសិស្សានុសិស្ស-និស្សិតក៏អាចវិលត្រឡប់ចូលរៀនវិញបានផងដែរ ។ ជាងនេះទៀត, ប្រជាពលរដ្ឋយ៉ាងច្រើនកុះករមានភាពសប្បាយរីករាយក្រៃលែង ក្នុងការចូលរួមអបអរសាទរពិធីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦ កាលពីប៉ុន្មានថ្ងៃកន្លងទៅនេះ ។

តាមរយៈរបាយការណ៍របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា, ខ្ញុំសូមសម្ដែងនូវការកោតសរសើរដ៏ស្មោះ ចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា, អង្គភាពក្រោមឱវាទ, មន្ទីរអប់រំ យុវជន និង កីឡារាជធានី-ខេត្ត និង គ្រឹះស្ថានសិក្សាទាំងអស់ ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម ក្នុងភាពបុរេសកម្ម និង ភាពប្រុងប្រយ័ត្នខ្ពស់, ដោយធានាបាននូវសុវត្ថិភាពល្អប្រសើរចំពោះសុខមាលភាពរបស់បុគ្គលិកអប់រំ និង ធានាបាននូវនិរន្តរភាពនៃការសិក្សារបស់សិស្សានុសិស្ស និង និស្សិត នៅក្នុងអំឡុងពេលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក៏ដូចជាបានដំណើរការឆ្នាំសិក្សាថ្មី ២០២១-២០២២ ដោយរលូនរហូតមកទល់ពេលនេះ ។

ខ្ញុំពិតជារីករាយ និង មានមោទនភាពខ្ពស់ ដោយបានកត់សម្គាល់ឃើញថា វិស័យអប់រំកំពុងបោះជំហានទៅរកទម្រង់នៃការអប់រំតាមបែបឌីជីថល ដែលទម្រង់នៃការអប់រំបែបនេះកំពុងឆ្លើយតបយ៉ាងប្រត្យក្ស ទៅនឹងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥ ។ ការប្រែក្លាយវិបត្តិទៅជាកាលានុវត្តភាពនាពេលនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយសារតែយុវជនយើងកំពុងត្រូវការសេវាអប់រំតាមបែបថ្មី, ទំនើប និង មានគុណភាពកម្រិតខ្ពស់ ជាពិសេស នៅពេលមានការកើនឡើងយ៉ាងឆាប់រហ័សនៃការ-ប្រើប្រាស់បច្ចេកវិទ្យា និង ប្រព័ន្ធអ៊ីនធើណិត ជាដើម ។ ការអភិវឌ្ឍសមត្ថភាពរបស់សិស្ស, និស្សិត, យុវជន និង ប្រជាជនទូទៅ ក្នុងការប្រើប្រាស់ និង ទទួលផលពីបច្ចេកវិទ្យាទាំងនេះប្រកបដោយប្រសិទ្ធភាព និង វៃឆ្លាត គឺជាកត្តាចាំបាច់ ដើម្បីធានានូវឧត្តមភាពប្រៀបធៀបរបស់កម្ពុជា នៅក្នុងតំបន់ និង សកលលោក ។

ខ្ញុំពិតជាគាំទ្រដល់គំនិតផ្ដួចផ្ដើមនៃការអប់រំតាមបែបឌីជីថល ដើម្បីពង្រឹងសមត្ថភាពផ្នែកអក្ខរកម្មឌីជីថលដល់សិស្ស, និស្សិត និង យុវជន ក្នុងគោលបំណងទាញប្រយោជន៍ពីសេដ្ឋកិច្ចឌីជីថល និង ធ្វើឱ្យយុវជនជំនាន់ក្រោយមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទាញយកប្រយោជន៍

ពីបច្ចេកវិទ្យាថ្មីៗ និង ទីផ្សារឌីជីថល ។ ខ្ញុំក៏សូមគាំទ្រដល់ការសម្រួចអាទិភាពសកម្មភាពដែលផ្តោតលើលទ្ធផល និង ការអនុវត្តការកែទម្រង់អប់រំដំណាក់កាលទី ៣ ដែលផ្តោតលើការកសាងប្រព័ន្ធ និង ការអភិវឌ្ឍសមត្ថភាព ដែលកិច្ចការទាំងនេះ ពិតជាឆ្លើយតបទៅនឹងការដ្ឋាននៃការងារកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់-កាល ទី ៤** ដើម្បីកំណើន, ការងារ, សមធម៌ និង ប្រសិទ្ធភាព ។

ខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណចំពោះអង្គការជាតិ, អង្គការអន្តរជាតិ, ដៃគូអភិវឌ្ឍន៍ផ្លូវការ, អង្គការមិនមែនរដ្ឋាភិបាល, វិស័យឯកជន និង សប្បុរសជនទាំងអស់ ដែលបានរួមចំណែកយ៉ាងសកម្ម ក្នុងការស្តារ, កសាង និង អភិវឌ្ឍវិស័យអប់រំ យុវជន និង កីឡានៅកម្ពុជា តាមរយៈការវិនិយោគ ក៏ដូចជាការផ្តល់នូវជំនួយឧបត្ថម្ភ និង ការគាំទ្រគ្រប់បែបយ៉ាង, ទាំងខាងសម្ភារៈ, ថវិកា និង បច្ចេកទេស, នាពេលកន្លងទៅ ជាពិសេស ក្នុងអំឡុងពេលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ។

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, អង្គសន្និបាតទាំងមូល, ជាទីមេត្រី!*

ឈរលើមូលដ្ឋាននៃសមិទ្ធផលអប់រំ និង ការកែទម្រង់វិស័យអប់រំទាំង ៣ ដំណាក់កាល ដែលក្រសួងអប់រំ យុវជន និង កីឡា បាន និង កំពុងអនុវត្ត រួមទាំងការដាក់ចេញនូវ **«ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣»** ដើម្បីចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពរឹងមាំ និង វិលត្រឡប់ទៅរកមាគ៌ានៃកំណើន និង ការអភិវឌ្ឍ ប្រកបដោយចីរភាពឡើងវិញ, វិស័យអប់រំពិតជាត្រូវការចាំបាច់នូវភាពជាអ្នកដឹកនាំ ដែលមានភាពវៃឆ្លាត, រស់រវើក, បុរេសកម្ម, និង ទន់ភ្លន់ ក្នុងការដោះស្រាយបញ្ហា និង ឆ្លើយតបភ្លាមៗចំពោះស្ថានការណ៍នៃវិបត្តិ ដែលបង្កឱ្យមានភាពរអាក់រអួលក្នុងការបង្រៀន និង ការរៀននៅទូទាំងប្រទេស ។ ប្រព័ន្ធអប់រំត្រូវមានភាពធន់ តាមរយៈភាពរស់រវើកក្នុងការកំណត់អាទិភាព, ទាំងផ្នែកចំណាយ និង ការបំពេញការងារ, រួមទាំងការចាប់យកឱកាស ដើម្បីប្រែក្លាយវិបត្តិទៅជាកាលានុវត្តភាព ក្នុងការកែទម្រង់, ចាប់យក ឬច្នៃប្រឌិតនូវវិធី (Method) និង វិធីសាស្ត្រ (Methodology) នៃការអប់រំ, ការ-បង្រៀន និង ការរៀន ។ ក្នុងន័យនេះ, ការអប់រំត្រូវមានភាពស្វាហាប់ និង ភាពឆ្លើយតប ដោយរួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិទ្យាទំនើបនៅក្នុងការបង្រៀន និង ការរៀន; ការបង្រៀន និង ការរៀនតាមបែបចម្រុះ; ការអនុវត្តកម្មវិធីសិក្សាដែលអាចបត់បែនបាន និង ផ្សារភ្ជាប់ទៅនឹងគន្លងអាជីព; ការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិន សំដៅភ្ជាប់ការអប់រំទៅនឹងការដោះស្រាយបញ្ហាជាក់ស្តែង; ការលើកកម្ពស់ទំនាក់ទំនងរវាងការសិក្សា និង ធុរកិច្ច តាមរយៈការបង្កើតគម្រោងរួមគ្នា និង ការ-

ស្រាវជ្រាវ; ការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា ដើម្បីដោះស្រាយការប្រែប្រួលនៃកម្លាំងពលកម្ម; និង ការចូលរួមលើកកម្ពស់ការសិក្សាពេញមួយជីវិត ។ល។

ជាការពិត, នៅក្នុងយុគសម័យនៃបដិវត្តឧស្សាហកម្មទី ៤ (IR 4), តម្រូវការសិក្សារបស់សិស្ស ក៏មានការផ្លាស់ប្តូរស៊ីជម្រៅផងដែរ ដោយសារសិស្សត្រូវការនូវ៖ (១)-របៀបរៀនបែបថ្មីសមស្របទៅនឹងវិធីសាស្ត្រថ្មីនៃការបង្រៀន; (២)-ការទទួលបាននូវការបណ្តុះបណ្តាលជំនាញថ្មីៗ ពិសេស ជំនាញឌីជីថល ដើម្បីដោះស្រាយបញ្ហាប្រឈមនៃសតវត្សទី ២១; និង (៣)-ការត្រៀមខ្លួនបានសមស្របសម្រាប់ទីផ្សារការងារដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។

ក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩, គ្រូបង្រៀនបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់និង ធានានិរន្តរភាពនៃការសិក្សាដល់សិស្សានុសិស្ស និង និស្សិតទាំងអស់ ហើយយើងទាំងអស់គ្នាក៏ទទួលស្គាល់ថា **គ្រូបង្រៀនគឺជាបេះដូងនៃការស្តារ និង អភិវឌ្ឍវិស័យអប់រំ** ផងដែរ ដោយសារតែគ្រូបង្រៀន បានខិតខំប្រឹងប្រែងសិក្សា និង ស្រាវជ្រាវ, ទាំងផ្នែកចំណេះដឹង, ជំនាញឌីជីថលនិង វិធីសាស្ត្របង្រៀនថ្មីៗ, តួយ៉ាងការខិតខំបង្រៀនពីចម្ងាយ ដើម្បីឱ្យសិស្សអាចរៀនសូត្រពីផ្ទះ ឬក្នុងករណីខ្លះ គ្រូបង្រៀនត្រូវធ្វើដំណើរទៅភូមិជនបទ និង បង្កើតជាក្រុមតូចៗ ដើម្បីឲ្យសិស្សអាចបន្តការសិក្សា ក្នុងអំឡុងពេលនៃការផ្អាកដំណើរការសាលារៀនជាបណ្តោះអាសន្ន ។ ដូច្នេះ, ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និង គណៈគ្រប់គ្រងសាលារៀន គឺជាកត្តាគន្លឹះមួយទៀត ដែលនាំទៅរកភាពជោគជ័យក្នុងការផ្តល់សេវាអប់រំ ប្រកបដោយការទទួលខុសត្រូវខ្ពស់ និង មានប្រសិទ្ធភាពនៅគ្រប់កាលៈទេសៈ ។ គ្រូបង្រៀននឹងបន្តដើរតួជាបុគ្គលនាំមុខ, ជាមគ្គុទ្ទេសក៍, ជាអ្នកស្រាវជ្រាវ, ជាទីប្រឹក្សា, និង ជាអ្នកច្នៃប្រឌិត ដែលចាំបាច់ត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពខ្លួនជាប្រចាំ, ទាំងផ្នែកចំណេះដឹង, ទាំងវិធីសាស្ត្របង្រៀន, រួមទាំងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង ភាសាបរទេស ដើម្បីយកចំណេះដឹងថ្មីៗ និង គរុកោសល្យថ្មីៗ មកបង្ហាត់បង្រៀនដល់សិស្ស-និស្សិត ឱ្យមានចំណេះដឹងទូលំទូលាយ និង អភិវឌ្ឍខ្លួនទៅជាពលរដ្ឋសកល និង ជាអ្នកបន្តវេនសម្រាប់អនាគត ។

ជាមួយគ្នានេះ, សាលារៀនត្រូវធានាឱ្យបាននូវបរិយាកាសសិក្សា ប្រកបដោយសុវត្ថិភាព, អនុវត្តកម្មវិធីសិក្សាបង្រួញ និង អាចបត់បែនបាន, ប្រើប្រាស់ខ្លឹមសារឌីជីថលសម្រាប់ការបង្រៀន និង ការរៀន ព្រមទាំងកែទម្រង់សាលារៀន ដើម្បីធ្វើឱ្យសាលារៀនមានការទទួលខុសត្រូវចំពោះឪពុកម្តាយសិស្ស និង សហគមន៍ តាមរយៈការផ្លាស់ប្តូរវប្បធម៌សាលារៀន និង ការលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍ ក្នុងការគ្រប់គ្រងសាលារៀន និង ការផ្តល់ការគាំទ្រសម្រាប់បរិយាកាសសិក្សា ប្រកបដោយសុវត្ថិភាព ។

*ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, អង្គសន្និបាតទាំងមូល, ជាទីមេត្រី!*

អង្គសន្និបាតអប់រំ ដែលកំពុងដំណើរការនាពេលនេះ គឺជាព្រឹត្តិការណ៍ប្រចាំឆ្នាំដ៏សំខាន់មួយ ដែលផ្ដល់ឱកាសឱ្យថ្នាក់ដឹកនាំ, អ្នករៀបចំគោលនយោបាយ និង អ្នកអនុវត្តនៅគ្រប់លំដាប់ថ្នាក់ បានមកជួបជុំគ្នា, ធ្វើការពិភាក្សា, ផ្លាស់ប្ដូរយោបល់, ផ្លាស់ប្ដូរចំណេះដឹង និង បទ-ពិសោធន៍ ដោយឈរលើមូលដ្ឋាននៃការបំពេញការងារក្នុងឆ្នាំសិក្សាកន្លងទៅ និង រិះរកវិធានការសម្រាប់អនុវត្តនៅឆ្នាំសិក្សាខាងមុខ ឱ្យកាន់តែមានគុណភាព និង ប្រសិទ្ធភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងសំណូមពរថ្មីៗ នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ជាតិ ។ ខ្ញុំរំពឹង និង ជឿជាក់យ៉ាងមុតមាំថា អង្គសន្និបាតដែលនឹងប្រព្រឹត្តទៅរយៈពេលបីថ្ងៃនេះ នឹងដំណើរការដោយរលូន និង ទទួលបាននូវផ្លែផ្កាតាមការរំពឹងទុក ។

ក្នុងនាមរាជរដ្ឋាភិបាល និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមថ្លែងអំណរគុណម្ដងទៀត ចំពោះថ្នាក់ដឹកនាំក្រសួង, បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់, ដៃគូអភិវឌ្ឍន៍ជាតិ និង អន្តរជាតិ, ព្រមទាំងអាជ្ញាធរមូលដ្ឋាន, វិស័យឯកជន, សប្បុរសជន និង សហគមន៍ទាំងអស់ ដែលបានសហការ និង ចូលរួមគាំទ្រយ៉ាងសកម្ម ដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ប្រកបដោយជោគជ័យក្នុងឆ្នាំសិក្សាកន្លងទៅ និង សូមលើកទឹកចិត្តឱ្យមានការបន្តផ្ដល់នូវការឧបត្ថម្ភ, ការគាំទ្រ និង ការ-ចូលរួមនេះតទៅមុខទៀត ដើម្បីជាឧត្តមប្រយោជន៍ដល់កុមារ និង យុវជនកម្ពុជាគ្រប់រូប ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សិស្សានុសិស្ស, និស្សិត, លោកគ្រូ, អ្នកគ្រូ និង អង្គសន្និបាតទាំងមូល សូមបានប្រកបដោយសុខភាពល្អ, ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច និង ចៀសផុតពីជំងឺកូវីដ-១៩ ។

ក្នុងនាម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណា-ចក្រកម្ពុជា**, ខ្ញុំសូមប្រកាសបើកជាផ្លូវការ នូវ **សន្និបាតបូកសរុបការងារអប់រំ យុវជន និង កីឡា ឆ្នាំសិក្សា ២០២០-២០២១ និង ទិសដៅសម្រាប់ឆ្នាំសិក្សា ២០២១-២០២២** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**